**ទម្រង់ការយល់ព្រមពីឪពុកម្ដាយ**

## ការអនុញ្ញាតប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការសម្ភាសន៍ ការប្រើប្រាស់រូបថត និងឈ្មោះរបស់សិស្ស

Providence Schools

ពេញមួយឆ្នាំសិក្សា សាលា Providence បង្កើតគម្រោងជាច្រើន ការងារសិស្ស សកម្មភាព ដំណើរកម្សាន្ត និងព្រឹត្តិការណ៍នានាដែលធ្វើឡើងនៅក្នុងសាលារបស់យើង។

ពេលខ្លះ យើងអាចដាក់រូបថតជាមួយអត្ថបទសម្រាប់កាសែត សៀវភៅឆ្នាំសិក្សា គេហទំព័រសាលា ឬមណ្ឌលសិក្សាធិការ និងសម្រាប់ដាក់តាំងនៅក្នុងសាលា ឬសហគមន៍។

ក្នុងឱកាសនោះ អ្នកថតរូបកាសែត និងបុគ្គលិកទូរទស្សន៍អាចធ្វើទស្សនកិច្ចនៅសាលាដើម្បីធ្វើកិច្ចសម្ភាសន៍សិស្សានុសិស្ស និងថតរូប ឬថតខ្សែអាត់រឿងព័ត៌មានដែលទាក់ទងនឹងសាលា ឬមណ្ឌលសិក្សាធិការ។ ដូច្នេះ មតិយោបល់ ឬរូបថតរបស់កូនអ្នកអាចបង្ហាញក្នុងកាសែត ឬនៅលើខ្សែវីដេអូសម្រាប់ទូរទស្សន៍។

ទោះជាយ៉ាងណាក៏ដោយ យើងនឹងមិនអនុញ្ញាតឱ្យមានរូបថត កិច្ចសម្ភាសន៍ ឬខ្សែវីដេអូរបស់កូនអ្នកដោយគ្មានការយល់ព្រមពីអ្នកឡើយ។

*សូមជ្រើសរើសជម្រើសមួយពីផ្នែកនីមួយៗខាងក្រោម ហើយចុះហត្ថលេខានៅខាងក្រោម។*

**ការងារ និងរូបថតសិស្ស**

– បាទ/ចាស ខ្ញុំផ្ដល់ការអនុញ្ញាតដល់សាលា Providence ដើម្បីបង្ហាញការងាររបស់កូនខ្ញុំជាមួយឈ្មោះ និងរូបថតសម្រាប់គោលបំណងព័ត៌មានសាធារណៈ (ឧទាហរណ៍ គេហទំព័រសាលារៀន និងមណ្ឌលសិក្សាធិការ កាសែត។ល។)

– ទេ ខ្ញុំមិនផ្ដល់ការអនុញ្ញាតឱ្យសាលា Providence បង្ហាញការងាររបស់កូនខ្ញុំជាមួយឈ្មោះ និងរូបថតសម្រាប់គោលបំណងព័ត៌មានសាធារណៈទេ។

**បទសម្ភាសន៍សិស្ស**

– បាទ/ចាស ខ្ញុំផ្ដល់ការអនុញ្ញាតឱ្យសម្ភាសកូនរបស់ខ្ញុំ និងបោះពុម្ព ឬកាត់ខ្សែអាត់ពីការសន្ទនាសម្រាប់គោលបំណងព័ត៌មានសាធារណៈ។

– ទេ ខ្ញុំមិនផ្ដល់ការអនុញ្ញាតឱ្យសម្ភាសកូនរបស់ខ្ញុំទេ ហើយនឹងមិនអនុញ្ញាតឱ្យមានការបោះពុម្ព ឬដកស្រង់ខ្សែអាត់ពីការសន្ទនាបែបនោះ ដើម្បីប្រើប្រាស់សម្រាប់គោលបំណងព័ត៌មានសាធារណៈឡើយ។

**វីដេអូរបស់សិស្ស**

– បាទ/ចាស ខ្ញុំផ្ដល់ការអនុញ្ញាតឱ្យថតវីដេអូកូនរបស់ខ្ញុំ។

– ទេ ខ្ញុំមិនផ្ដល់ការអនុញ្ញាតឱ្យថតវីដេអូកូនរបស់ខ្ញុំទេ។

នាមត្រកូលរបស់សិស្ស ______________________ នាមខ្លួន ______________________

នាមត្រកូលឪពុកម្ដាយ ______________________ នាមខ្លួន ______________________

ហត្ថលេខាមាតាបិតា ______________________ កាលបរិច្ឆេទ ______________________